# ហាន់តាវីរុស (Hantavirus)

តារាងទិន្នន័យ



ហាន់តាវីរុស គឺជាក្រុមនៃវីរុសដែលភាគច្រើនផ្ទុកដោយសត្វកកេរខ្លះៗ។ នៅសហរដ្ឋអាមេរិក នេះរួមមានកណ្តុរ និងកណ្តុរតូចមួយចំនួន។ ការឆ្លងហាន់តាវីរុសអាចបង្កឱ្យមានរោគសញ្ញាផ្សេងៗ។



ហាន់តាវីរុសរាលដាលតាមរយៈការដកដង្ហើមយកទឹកមាត់ ទឹកនោម លាមក ឬសម្ភារៈសំបុករបស់សត្វកកេរដែលមានមេរោគ និងស្ថិតនៅក្នុងខ្យល់។ វាកម្រណាស់ដែលការខាំរបស់សត្វកកេរអាចបង្កឱ្យមានហាន់តាវីរុស។ ជាទូទៅ វាមិនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទេ។

## សញ្ញា និងរោគសញ្ញា



គ្រុនក្តៅ និងញាក់



ឈឺសាច់ដុំ



ឈឺក្បាល



ចង្អោរ និងក្អួត



រាគ



ក្អក

រោគសញ្ញាក៏អាចរួមមានវិលមុខផងដែរ។ ក្នុងករណីធ្ងន់ធ្ងរ ការដកដង្ហើមខ្លី និងការក្អកអាចនាំឱ្យមានការប្រមូលផ្តុំទឹកក្នុងសួត និងការខ្វះអុកស៊ីសែនធ្ងន់ធ្ងរនៅក្នុងឈាម។ រោគសញ្ញាជាទូទៅចាប់ផ្តើមពីមួយសប្តាហ៍ទៅប្រាំបីសប្តាហ៍បន្ទាប់ពីការប៉ះពាល់។



សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកមានសញ្ញា និងរោគសញ្ញាទាំងនេះ បន្ទាប់ពីការប៉ះពាល់ជាមួយសត្វកកេរ។ មិនមានការព្យាបាលសម្រាប់ហាន់តាវីរុសទេ។

# ការការពារហាន់តាវីរុស

វិធីល្អបំផុតដើម្បីការពារហាន់តាវីរុស គឺត្រូវកម្ចាត់ប្រភពអាហារ ទឹក និងវត្ថុដែលផ្តល់ជាជម្រកដល់សត្វកកេរ។



### បិទជិត

បិទរន្ធ ឬចន្លោះនៅខាងក្នុង និងខាងក្រៅផ្ទះ



### ដាក់អន្ទាក់

ប្រើអន្ទាក់បក់ដើម្បីចាប់ កណ្តុរ និងកណ្តុរតូច



### សម្អាត

កម្ចាត់ប្រភពអាហារដែលអាច ជាអាហាររបស់សត្វកកេរ

### ដើម្បីសម្អាតភស្តុតាងនៃសត្វកកេរ៖



បើកទ្វារ និងបង្អួច ដើម្បីឱ្យខ្យល់ស្រស់ចូលយ៉ាងហោចណាស់ 30 នាទី **មុនពេល** សម្អាតតំបន់នោះ



ពាក់ស្រោមដៃ និងម៉ាស់ធូលី **មុនពេល** សម្អាត



កុំប្រើម៉ាស៊ីនបូមធូលី ឬអំបោស ដើម្បីសម្អាត លាមក ឬសម្ភារៈសំបុក



បាញ់លាមកសត្វកកេរ ជាមួយទឹកលាយសារធាតុប្លិច ហើយបន្ទាប់មកប្រើក្រដាសជូតដើម្បីយកទឹកនោម និងលាមក

## សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖



1. www.maine.gov/dhhs/hantavirus
2. www.cdc.gov/hantavirus
3. www.cdc.gov/healthy-pets/rodent-control/

អ្នកក៏អាចហៅទូរស័ព្ទទៅ Maine CDC តាមលេខ 1-800-821-5821។

បានធ្វើបច្ចុប្បន្នភាព ខែសីហា ឆ្នាំ 2024

អៃខុនពី www.flaticon.com